# មហាតំបន់ស៊ីដនីភាគខាងលិច (GREATER WESTERN SYDNEY)

# ស្មៅចង្រៃជាអាទិភាព



Khmer | ភាសាខ្មែរ

FairfieldCity
Celebrating diversity

# ទំព័រមាតិកា៖

**ទំព័រលេខ៖**


ទិដ្ឋភាពទូទៅ .......... 5

ព័ត៌មានអំពីការត្រួតពិនិត្យស្មៅចង្រៃជាអាទិភាព .......... 6

ដំណើរការត្រួតពិនិត្យអចលនទ្រព្យឯកជន .......... 7

ស្មៅចង្រៃជាអាទិភាពរបស់រដ្ឋ៖ ការបង្ការ .......... 8

ស្មៅចង្រៃជាអាទិភាពរបស់រដ្ឋ៖ ការលុបបំបាត់ / ការបង្ក្រាប .......... 10

ស្មៅចង្រៃជាអាទិភាពរបស់រដ្ឋ៖ ការបង្ក្រាប .......... 11

ស្មៅចង្រៃជាអាទិភាពនៅក្នុងតំបន់៖ ការបង្ការ .......... 13

ស្មៅចង្រៃអាទិភាពនៅក្នុងតំបន់៖ ការលុបបំបាត់ .......... 14

ស្មៅចង្រៃជាអាទិភាពនៅក្នុងតំបន់៖ ការបង្ក្រាប .......... 16

ស្មៅចង្រៃជាអាទិភាពនៅក្នុងតំបន់៖ ការការពារទ្រព្យសម្បត្តិ .......... 17

វិធីសាស្ត្រគ្រប់គ្រងស្មៅចង្រៃ .......... 18

ចំណាំ .......... 21


ដើមដើមធំពេតស្លឹកតូច

# ទិដ្ឋភាពទូទៅ

ស្មៅចង្រៃជាអាទិភាពនៅក្នុងតំបន់រដ្ឋាភិបាលមូលដ្ឋានទីក្រុង Fairfield (LGA) គឺជារុក្ខជាតិដែលមានសក្ដានុពលក្នុងការបង្កហានិភ័យជីវសន្តិសុខដល់សុខភាពមនុស្ស សេដ្ឋកិច្ច ភាពរស់រវើកនៃទីក្រុង និងបរិស្ថានរបស់យើង។

នៅរដ្ឋញូសោវែល (NSW) ការត្រួតត្រាការគ្រប់គ្រងស្មៅចង្រៃជាអាទិភាពគឺជាការទទួលខុសត្រូវរបស់រដ្ឋាភិបាលរដ្ឋនៅក្រោម *ច្បាប់ជីវសន្តិសុខឆ្នាំ 2015*។

កាតព្វកិច្ចទាំងនេះត្រូវបានប្រកាន់ខ្ជាប់តាមរយៈការគ្រប់គ្រងស្មៅចង្រៃជាអាទិភាពលើដីសាធារណៈ និងការត្រួតពិនិត្យដីឯកជន ដើម្បីធានាថាម្ចាស់ ឬអ្នកកាន់កាប់ដីអនុវត្តការគ្រប់គ្រងលើស្មៅចង្រៃជាអាទិភាពនៅលើដីរបស់ពួកគេ ដើម្បីគ្រប់គ្រងហានិភ័យជីវសន្តិសុខ។

កម្មវិធីទាំងនេះស្វែងរកការប្រើប្រាស់ធនធានដែលមានកំណត់របស់យើង ដើម្បីបង្កើនបានជាអតិបរមានូវការបង្ក្រាបស្មៅចង្រៃជាអាទិភាពតាមវិធីសាស្ត្រជាយុទ្ធសាស្ត្រមួយ។ យុទ្ធសាស្ត្រគ្រប់គ្រងស្មៅចង្រៃឱ្យមានប្រសិទ្ធភាព និងសក្តិសិទ្ធបំផុតគឺការបង្ការ។

ការងារត្រួតពិនិត្យ និងគ្រប់គ្រងចរបស់សាលាសង្កាត់គឺផ្តោតលើផ្នែកនានាដូចខាងក្រោម៖

- នៅតាមបណ្ដោយផ្លូវបង្ហូរទឹក
- ព្រៃក ឬអូរធម្មជាតិតូចៗ និង
- នៅជាប់នឹងដីព្រៃបម្រុង។

ការគ្រប់គ្រងស្មៅចង្រៃប្រកបដោយជោគជ័យពឹងផ្អែកលើការតាមដាន បន្ទាប់ពីកិច្ចខិតខំប្រឹងប្រែងក្នុងការដកយកចេញដំបូង។

## របៀបដែលស្មៅចង្រៃរីករាលដាល

ស្មៅចង្រៃបំផ្លាញប្រព័ន្ធអេកូធម្មជាតិ និងដាក់កំហិតលើការប្រើប្រាស់ដីឱ្យបានល្អបំផុត។

ស្មៅចង្រៃត្រូវបានរីករាលដាលដោយយន្តការជាច្រើន៖

- ការចាក់ចោលកំណាត់មែកឈើតូចៗពីសួនច្បារទៅលើផ្លូវបម្រុង ដីទំនេរ លើរបង ឬនៅក្បែរព្រៃគម្ពោត
- បក្សី និងសត្វនានានាំយកស្មៅចង្រៃទាំងនោះមកជាប់តាមស្លាប រោម និងតាមរយៈប្រព័ន្ធរំលាយអាហាររបស់វា
- ខ្យល់ ទឹក និងសំណើក។

## វិធីបង្ការការរីករាលដាល

ដើម្បីបង្ការការរីករាលដាលនៃស្មៅចង្រៃនៅក្នុងតំបន់ទីក្រុង និងតំបន់ជនបទរបស់យើងនៅទីក្រុង Fairfield៖

បញ្ឈប់ការចោលសំរាមសួនច្បារពាសដោយមិនប្រុងប្រយ័ត្ន។

ស្វែងយល់ថាតើស្មៅចង្រៃណាខ្លះអាចធ្វើទៅជាជីកំប៉ុសដោយសុវត្ថិភាព ហើយស្មៅចង្រៃណាខ្លះត្រូវយកទៅកន្លែងចាក់សំរាមតែប៉ុណ្ណោះ។

សម្អាតឧបករណ៍ថែសួនដែលអ្នកបានប្រើវានៅលើស្មៅ ដើម្បីបង្ការការដឹកជញ្ជូនគ្រាប់ពូជ។

## របៀបដែលស្មៅចង្រៃអាចប៉ះពាល់ដល់សុខភាពរបស់អ្នក

ប្រភេទរុក្ខជាតិផ្សេងៗគ្នាអាចប៉ះពាល់ដល់សុខភាពដោយបង្កឱ្យមានជំងឺហឺត រោគផ្តាសាយតឹងច្រមុះ រោគរលាកស្បែក ជំងឺភ្នែកក្រហម និងរោគភ្នែកមានភាពរសើបចំពោះកាំរស្មី (ពន្លឺ)។

រុក្ខជាតិផ្សេងទៀតមានបន្លាដែលអាចចោះទាំងស្បែកសត្វ និងស្បែកមនុស្ស។ នេះអាចបណ្តាលឱ្យរងរបួសរាងកាយ។

## របៀបដែលស្មៅចង្រៃអាចប៉ះពាល់ដល់បរិស្ថាន

នៅតំបន់ដីគម្ពោត និងតំបន់ធម្មជាតិ ស្មៅចង្រៃអាចបង្ក្រាបរុក្ខជាតិក្នុងស្រុក ហើយដុះប្រកួតប្រជែងដណ្តើមលំហ ពន្លឺ និងទឹកពីរុក្ខជាតិក្នុងស្រុក។ ស្មៅចង្រៃក៏អាចផ្លាស់ប្តូរវដ្តនៃសារធាតុចិញ្ចឹម ភាពចម្រុះនៃរុក្ខជាតិ សត្វ និងវដ្តនៃទឹកផងដែរ។

## របៀបដែលស្មៅចង្រៃអាចប៉ះពាល់ដល់សេដ្ឋកិច្ច

ស្មៅចង្រៃកាត់បន្ថយតម្លៃ គុណភាព និងបរិមាណផលិតផលដំណាំពីវិស័យកសិកម្ម។ ស្មៅចង្រៃក៏មានផលប៉ះពាល់សេដ្ឋកិច្ចលើវិស័យទេសចរណ៍ និងលក្ខណៈពិសេសនៃទេសភាពដែលជំរុញឱ្យមានភាពទាក់ទាញផងដែរ។

## អ្វីដែលត្រូវធ្វើប្រសិនបើអ្នកទទួលបានការជូនដំណឹង

ប្រសិនបើអ្នកបានទទួលការជូនដំណឹងពីសាលាសង្កាត់ទាក់ទងនឹងការត្រួតពិនិត្យអចលទ្រព្យរបស់អ្នក (នៅក្រោមផ្នែកទី 98) សូមសូមកុំទើសទាល់ក្នុងការទាក់ទងសាលាសង្កាត់ ដើម្បីរៀបចំពេលវេលាសមស្របនឹងអ្នក បើមិនដូច្នេះទេ ការត្រួតពិនិត្យនឹងប្រព្រឹត្តទៅនៅចន្លោះកាលបរិច្ឆេទដែលបានផ្តល់ឱ្យនៅលើការជូនដំណឹងនោះ។

# ការត្រួតពិនិត្យស្មៅចង្រៃជាអាទិភាព

នៅក្រោមផ្នែកទី 3 *នៃច្បាប់ជីវសន្តិសុខឆ្នាំ* 2015 - កាតព្វកិច្ចទូទៅនៃជីវសន្តិសុខចែងថាបុគ្គលណាម្នាក់ដែលដឹង ឬគួរតែដឹងដោយសមហេតុផលពីហានិភ័យជីវសន្តិសុខដែលបង្កឡើង ឬទំនងជាត្រូវបានបង្កឡើងដោយដោយសារជាតុជីវសន្តិសុខនៅលើដីរបស់ពួកគេ មានការព្វកិច្ចដើម្បីធានាថា ដល់កម្រិតដែលអាចអនុវត្តបានដោយសមហេតុផល ត្រូវទប់ស្កាត់ លុបបំបាត់ ឬកាត់បន្ថយហានិភ័យជីវសន្តិសុខនោះ។

## ដំណើរការ

តំបន់ត្រូវបានត្រួតពិនិត្យដោយប្រើមធ្យោបាយនៃវិធីសាស្ត្រគោលដៅរួមទាំងដីទាំងអស់ដោយមិនគិតពីកម្មសិទ្ធិ ឬការកាន់កាប់ទេ។

- រាល់ការចូលទៅលើដីឯកជនត្រូវអនុវត្តទៅតាមផ្នែកទី 98 *នៃច្បាប់ជីវសន្តិសុខឆ្នាំ* 2015។

- ម្ចាស់ដីឯកជន និងអ្នកកាន់កាប់ក្នុងតំបន់ដែលបានជ្រើសរើសនឹងត្រូវបានចេញលិខិតមួយដោយណែនាំថា ការត្រួតពិនិត្យអចលនទ្រព្យរបស់ពួកគេនឹងធ្វើឡើងដើម្បីកំណត់អត្តសញ្ញាណស្មៅចង្រៃជាអាទិភាពណាមួយ។

- នៅពេលត្រួតពិនិត្យ ប្រសិនបើស្មៅចង្រៃជាអាទិភាពណាមួយត្រូវបានកំណត់ឃើញនៅលើអចលនទ្រព្យរបស់អ្នក សំណាកនៃប្រភេទស្មៅចង្រៃនីមួយៗនឹងត្រូវបានដាក់ស្លាកដោយបង់បិទភ្ជាប់ពណ៌ផ្កាឈូក ដើម្បីជួយអ្នកកំណត់អត្តសញ្ញាណស្មៅចង្រៃទាំងនោះ និងស្មៅចង្រៃផ្សេងទៀតដែលអាចកើតមាននៅលើអចលនទ្រព្យ។

- ប្រសិនបើស្មៅចង្រៃត្រូវបានកំណត់អត្តសញ្ញាណ អ្នកនឹងត្រូវបានគេចេញលិខិត "វត្តមានស្មៅចង្រៃជាអាទិភាព" ហើយត្រូវបានស្នើសុំឱ្យគ្រប់គ្រងស្មៅចង្រៃដោយស្ម័គ្រចិត្តនៅក្នុងរយៈពេលកំណត់ដែលនឹងត្រូវបានកំណត់នៅក្នុងលិខិតនោះ។ កាលបរិច្ឆេទនៃការត្រួតពិនិត្យឡើងវិញក៏នឹងត្រូវបានផ្តល់ផងដែរ។ លិខិតនឹងរួមបញ្ចូលបញ្ជីនៃស្មៅចង្រៃដែលបានរកឃើញ ហើយអ្នកនឹងត្រូវបានផ្តល់ព័ត៌មានដើម្បីជួយអ្នកក្នុងការគ្រប់គ្រងរបស់វា។

- ប្រសិនបើអ្នកត្រូវការជំនួយទាក់ទងនឹងផ្នែកណាមួយនៃលិខិត "វត្តមានស្មៅចង្រៃជាអាទិភាព" សូមទាក់ទងសាលាក្រុង Fairfield តាមទូរសព្ទលេខ 9725 0222។



*ដើមបន្លាដំបងយក្ស Tiger pear*

# ក្រុមការងារស្មៅចង្រៃជីវសន្តិសុខ

ដំណើរការត្រួតពិនិត្យអចលនទ្រព្យឯកជន *ច្បាប់ជីវសន្តិសុខឆ្នាំ 2015*

**"សេចក្តីជូនដំណឹងអំពីការត្រួតពិនិត្យ" - មិនមានបទប្បញ្ញត្តិ**

**បានត្រួតពិនិត្យ**

**រកមិនឃើញស្មៅចង្រៃទេ**
បានបញ្ចប់

**បានរកឃើញស្មៅចង្រៃជាអាទិភាព**
លិខិតអំពី "វត្តមានស្មៅចង្រៃជាអាទិភាព" ត្រូវបានចេញជាលិខិតមិនមានបទប្បញ្ញត្តិ

**បានត្រួតពិនិត្យ**

**រកមិនឃើញស្មៅចង្រៃទេ**
បានបញ្ចប់

**បានរកឃើញស្មៅចង្រៃជាអាទិភាព**
លិខិតអំពី "វត្តមានស្មៅចង្រៃជាអាទិភាព" ត្រូវបានចេញជាលិខិតមិនមានបទប្បញ្ញត្តិ

**មិនបានគ្រប់គ្រងស្មៅចង្រៃ**
លិខិត "គោលបំណងក្នុងការចេញការណែនាំអំពីជីវសន្តិសុខ" ត្រូវបានផ្ញើដើម្បីអនុញ្ញាតឱ្យមានពេលប្រហែល 4 សប្តាហ៍សម្រាប់ការងារដែលនឹងត្រូវអនុវត្តមុនពេលចេញសេចក្តីណែនាំអំពីជីវសន្តិសុខ។

**បានត្រួតពិនិត្យ**

**រកមិនឃើញស្មៅចង្រៃទេ**
បានបញ្ចប់

**គ្មានការងារបន្ថែមទៀតត្រូវបានទទួលធ្វើទេ**
“ការណែនាំអំពីជីវសន្តិសុខ” ដែលបានចេញនៅក្រោម *ផ្នែកទី 128 នៃច្បាប់ជីវសន្តិសុខឆ្នាំ 2015*។
ការខកខានក្នុងការអនុលោមតាមសេចក្តីជូនដំណឹងនេះគឺជាបទល្មើសប្រភេទទី 2 នៅក្រោមផ្នែកទី 138 នៃច្បាប់នេះ

**បានត្រួតពិនិត្យ**

**រកមិនឃើញស្មៅចង្រៃទេ**
បានបញ្ចប់

**គ្មានការងារត្រូវបានទទួលធ្វើទេ**
“ផ្នែកទី 133 - ទទួលព្រមធ្វើការងារដែលតម្រូវ និងការស្តារឡើងវិញនូវការចំណាយនានា”
សេចក្តីជូនដំណឹងត្រូវបានចេញដោយអនុលោមតាម*ច្បាប់ជីវសន្តិសុខឆ្នាំ 2015*។

# ស្មៅចង្រៃជាអាទិភាពរបស់រដ្ឋ៖ ការបង្ការ

● ទំនាក់ទំនងជាមួយសាលាសង្កាត់



**Black knapweed**

*Centaurea x moncktoni*



**Bridal veil creeper**

*Asparagus declinatus*



**Eurasion water milfoil**

*Myriophyllum spicatum*

ប្រជាពលរដ្ឋមានកាតព្វកិច្ចដែលអាចអនុវត្តតាមផ្លូវច្បាប់ដើម្បីបង្ការ លុបបំបាត់ និងកាត់បន្ថយហានិភ័យជីវសន្តិសុខដែលបង្កឡើងដោយសារធាតុដែលបានហាមឃាត់។

ប្រជាពលរដ្ឋត្រូវជូនដំណឹងដល់អាជ្ញាធរត្រួតពិនិត្យនៅមូលដ្ឋានអំពីវត្តមាននៃសារធាតុដែលបានហាមឃាត់ ឬបានសង្ស័យថាជាសារធាតុដែលបានហាមឃាត់។



**រុក្ខជាតិអណ្តែតលើទឹកស្លឹកតូចៗ (Frogbit) / រុក្ខជាតិអេប៉ុង (Sponge plant)**

*Limnobium spp. (គ្រប់ប្រភេទ)*



**ស្មៅ Gamba**

*Andropogon gayanus*



**Hawkweed**

*Pilosella spp. (ប្រភេទទាំងអស់លើកលែងតែ Hieracium murorum)*



**Hydrocotyle / Water pennywort**
*Hydrocotyle ranunculoides*



**ស្មៅរោមសត្វម៉ិកស៊ិក**
**(Mexican feather grass)**
*Nassella tenuissima*
*(syn. Stipa tenuissima)*



**ស្មៅចង្រៃ Parthenium**
*Parthenium hysterophorus*



**ផ្លែប៉ោម Pond apple**
*Annona glabra*



**Knapweed ដែលបានរកឃើញ**
*Centaurea stoebe subsp. australis*



**Water caltrop**
*Trapa spp. (គ្រប់ប្រភេទ)*



**Water soldier**
*Stratiotes aloides*



**Yellow burrhead**
*Limnocharis flava*

# ស្មៅចង្រៃជាអាទិភាពរបស់រដ្ឋ៖ ការលុបបំបាត់

*វិធានការគ្រប់គ្រង៖ ត្រូវលុបបំបាត់រុក្ខជាតិពីដី ហើយបង្ក្រាប និងបំផ្លាញវាជាបន្តបន្ទាប់ ហើយត្រូវរក្សាដីទុកមិនឱ្យមានរុក្ខជាតិនេះ។ មិនត្រូវលក់រុក្ខជាតិនានានៅក្នុងរដ្ឋ NSW។*

🟠 កាត់ និងលាបពណ៌ 🟣 ការព្យាបាលដោយប្រើថ្នាំសម្លាប់ស្មៅ - ការជូតដើម 🟢 ការដកចេញដោយដៃ 🟢 ការបាញ់ថ្នាំ 🟤 ការដកចេញដោយម៉ាស៊ីន
🔴 ទំនាក់ទំនងជាមួយសាលាសង្កាត់ 🩷 ដីសម្រាប់ចិញ្ចឹមសត្វដែលស៊ីស្មៅជាអាហារ ⚫ ការត្រួតកាប់ និងការដាក់សំរាមគ្របកុំឱ្យដីហួត



**Bitou bush**

*Chrysanthemoides monilifera subsp. Rotundata*



**Boneseed**

*Chrysanthemoides monilifera subsp. Monilifera*



**ផ្លែប៉ោមសូដាត្រូពិច (Tropical soda apple)**

*Solanum viarum*

# ស្មៅចង្រៃជាអាទិភាពរបស់រដ្ឋ៖ ការបង្ក្រាប

*វិធានការគ្រប់គ្រង៖* ត្រូវលុបបំបាត់រុក្ខជាតិពីដី ហើយបង្ក្រាប និងបំផ្លាញវាជាបន្តបន្ទាប់ ហើយត្រូវរក្សាដីទុកមិនឱ្យមានរុក្ខជាតិនេះ។ មិនត្រូវលក់រុក្ខជាតិនានានៅក្នុងរដ្ឋ NSW។

🟠 កាត់ និងលាបពណ៌ 🟡 ការចាក់ និងការបំពេញដើម 🟣 ការព្យាបាលដោយប្រើថ្នាំសម្លាប់ស្មៅ - ការជូតដើម 🟣 ការស្រោបផ្នែកដើមដែលជាប់ឫស
🟢 ការបាញ់ថ្នាំ 🟤 ការដកចេញដោយម៉ាស៊ីន 🔴 ទំនាក់ទំនងជាមួយសាលាសង្កាត់ 🩷 ដីសម្រាប់ចិញ្ចឹមសត្វដែលស៊ីស្មៅជាអាហារ
🩷 ការត្រួតកាប់ និងការដាក់សំរាមគ្របកុំឱ្យដីហួត ⚫ កាត់ផ្នែកដើមដែលជាប់ឫស



**African boxthorn**

*Lycium ferocissimum*



**ស្មៅចង្រៃ Asparagus**

*Asparagus aethiopicus*



**Blackberry**

*Rubus fruticosus app.*

# ស្មៅចង្រៃជាអាទិភាពរបស់រដ្ឋ៖ ការបង្ក្រាប

*វិធានការគ្រប់គ្រង៖* ត្រូវលុបបំបាត់រុក្ខជាតិពីដី ហើយបង្ក្រាប និងបំផ្លាញវាជាបន្តបន្ទាប់ ហើយត្រូវរក្សាដីទុកមិនឱ្យមានរុក្ខជាតិនេះ។ មិនត្រូវលក់រុក្ខជាតិនានានៅក្នុងរដ្ឋ NSW។



**Cape broom**

*Genista monspessulana*



**Cabomba**

*Cabomba caroliniana*



**Cat’s claw creeper**

*Dolichandra unguis-cati*



**Chilean needle grass**

*Nassella neesiana*



**Fireweed**

*Senecio madagascariensis*



**Gorse**

*Ulex europaeus*



**Lantana**

*Lantana camara*

- កាត់ និងលាបពណ៌
- ការចាក់ និងការបំពេញដើម
- ការដកចេញដោយដៃ
- កោស និងលាបពណ៌
- ការបាញ់ថ្នាំ
- ការដកចេញដោយម៉ាស៊ីន
- ទំនាក់ទំនងជាមួយសាលាសង្កាត់
- ការគ្រវាត់កាប់ និងការដាក់សំរាមគ្របកុំឱ្យដីហួត
- ការគ្រប់គ្រងជីវសាស្រ្ត



**ដើមវល្លិ Madeira vine**

*Anredera cordifolia*

# ស្មៅចង្រៃជាអាទិភាពរបស់រដ្ឋ៖ ការបង្ក្រាប

*វិធានការគ្រប់គ្រង៖* ត្រូវលុបបំបាត់រុក្ខជាតិពីដី ហើយបង្ក្រាប និងបំផ្លាញវាជាបន្តបន្ទាប់ ហើយត្រូវរក្សាដីទុកមិនឱ្យមានរុក្ខជាតិនេះ។ មិនត្រូវលក់រុក្ខជាតិនានានៅក្នុងរដ្ឋ NSW។



**ផ្លែដំបងយក្ខ Prickly pear (ធម្មតា)**

Opuntia spp. (មិនរាប់បញ្ចូល O.ficus-indica), Cylindropuntia spp. និង Austrocylindropuntia

**ដំបងយក្ខ Smooth tree pear**

*Opuntia monacantha*





**Sagittaria**

*Sagittaria platyphylla*



**Salvinia**

*Salvinia molesta*



**Serrated tussock**

*Nassella trichotoma*



**ដើមស្វូល (Willows)**

*ប្រភេទ Salix លើកលែងតែ S. babylonica, S. X calodendron និង S. x reichardtii (willows លើកលែងតែ weeping willow, pussy willow និង sterile pussy willow)*

- កាត់ និងលាបពណ៌
- ការចាក់ និងការបំពេញដើម
- ការដកចេញដោយដៃ
- ការស្រោបផ្នែកដើមដែលជាប់ឬស
- ការបាញ់ថ្នាំ
- ការដកចេញដោយម៉ាស៊ីន
- ទំនាក់ទំនងជាមួយសាលាសង្កាត់
- ការគ្រប់គ្រងជីវសាស្ត្រ

# ស្មៅចង្រៃជាអាទិភាពនៅក្នុងតំបន់៖ ការបង្ការ

***សារធាតុដែលបានហាមឃាត់៖*** វាជាបទល្មើសក្នុងការលក់ដូរប្រភេទស្មៅចង្រៃណាមួយដែលបានហាមឃាត់នានាដែលមានរាយក្នុងតារាងទី 2 ផ្នែកទី 1 *នៃច្បាប់ជីវសន្តិសុខរដ្ឋ NSW ឆ្នាំ 2015។*



**hygrophila ឥណ្ឌាខាងកើត**

*Hygrophila polysperma*



**ស្មៅកន្ទុយកណ្តុរយក្ខ (Giant rats tail grass)**

*Sporobolus pyramidalis*



**Spanish broom**

*Spartium junceum*

ស្មៅចង្រៃទាំងនេះបច្ចុប្បន្នមិនត្រូវបានគេរកឃើញនៅក្នុងតំបន់ បង្កហានិភ័យជីវសន្តិសុខដ៏សំខាន់ និងការទប់ស្កាត់ហានិភ័យជីវសន្តិសុខដែលបង្កឡើងដោយស្មៅចង្រៃទាំងនេះគឺជាគោលបំណងជាក់ស្តែងដែលសមហេតុផល។

មិនត្រូវលក់នៅក្នុងមហាតំបន់ស៊ីដនី (Greater Sydney) ទេ។

- កាត់ និងលាបពណ៌
- ការដកចេញដោយដៃ
- ការស្រោបផ្នែកដើមដែលជាប់ឫស
- ការបាញ់ថ្នាំ
- ការដកចេញដោយម៉ាស៊ីន
- ទំនាក់ទំនងជាមួយសាលាសង្កាត់
- ការគ្រប់គ្រងជីវសាស្ត្រ



**ចកទឹក (Water lettuce)**

*Pistia stratiotes*



**ស្មៅ Water star grass**

*Heteranthera zosterifolia*

# ស្មៅចង្រៃអាទិភាពនៅក្នុងតំបន់៖ ការលុបបំបាត់



**ស្មៅចង្រៃ Chinese knotweed**

*Persicaria chinensis*



**Climbing asparagus**

*Asparagus africanus*



**Coral creeper**

*Barleria repens*



**Glory lily**

Gloriosa superba



**Grey sallow**

*Salix cinerea*



**Groundsel bush**

*Baccharis halimifolia*



**Holly-leaved senecio**

*Senecio glastifolius*



**Kei apple**

*Dovyalis caffra*



**Kidney leaf mud plantain**

*Heteranthera reniformis*



**Leaf cactus**

*Pereskia aculeata*



**Ming asparagus fern**

*Asparagus macowanii var.*



**Nodding thistle**

*Carduus nutans subsp. nutans*



**ដើមវល្លិ Skunk vine**

*Paederia foetida*

<u>គោលបំណងនៃការគ្រប់គ្រងសម្រាប់តំបន់ស៊ីដនី</u>

ស្មៅចង្រៃទាំងនេះឃើញមានក្នុងការចែកចាយដ៏កំណត់។

អាទិភាពក្នុងតំបន់គឺការលុបបំបាត់ស្មៅចង្រៃទាំងនេះចេញពីមហាតំបន់ស៊ីដនី។

កាត់ និងលាបពណ៌ · ការចាក់ និងការបំពេញដើម · ការដកចេញដោយដៃ · កោស និងលាបពណ៌ · ការស្រោបផ្នែកដើមដែលជាប់ឫស

ការបាញ់ថ្នាំ · ការដកចេញដោយម៉ាស៊ីន · ទំនាក់ទំនងជាមួយសាលាសង្កាត់ · ការគ្រវាត់កាប់ និងការដាក់សំរាមគ្របកុំឱ្យដីហួត

ការគ្រប់គ្រងជីវសាស្ត្រ

# ស្មៅចង្រៃជាអាទិភាពនៅក្នុងតំបន់៖ ការបង្ក្រាប

*វិធានការគ្រប់គ្រង៖* ដើម្បីទប់ស្កាត់ការរីករាលដាលនៃប្រភេទពូជនានានៅគ្រប់តំបន់ ឬផ្នែកទាំងអស់។ ផ្នែកទី 2។ ផ្នែកទី 69 (f) *នៃច្បាប់ជីវសន្តិសុខរដ្ឋ NSW ឆ្នាំ 2015។*



**African Olive**

*Olea europaea subsp. cusidata*



**Asparagus fern**

*Asparagus virgatus*



**Black willow**

*Salix nigra*



**Senegal tea**

*Gymnocoronis spilanthoides*



**Sicklethorn**

*Asparagus falcatus*



**ដើមបន្លាដំបងយក្ស Tiger pear**

*Opuntia aurantiaca*



**Water poppy**

*Hydrocleys nymphoides*

- កាត់ និងលាបពណ៌
- ការដកចេញដោយដៃ
- ការស្រោបផ្នែកដើមដែលជាប់ឫស
- ការបាញ់ថ្នាំ
- ការដកចេញដោយម៉ាស៊ីន
- ទំនាក់ទំនងជាមួយសាលាសង្កាត់
- ការគ្រវាត់កាប់ និងការដាក់សំរាមគ្របកុំឱ្យដីហួត

# ស្មៅចង្រៃជាអាទិភាពនៅក្នុងតំបន់៖ ការការពារទ្រព្យសម្បត្តិ

*វិធានការគ្រប់គ្រង៖* ដើម្បីទប់ស្កាត់ការរីករាលដាលនៃស្មៅចង្រៃទៅកាន់ទីតាំងសំខាន់ៗ/ទ្រព្យសម្បត្តិដែលមានតម្លៃសេដ្ឋកិច្ចខ្ពស់ ឬកាត់បន្ថយផលប៉ះពាល់របស់វាទៅលើទីកន្លែងទាំងនេះ ប្រសិនបើការរីករាលដាលបានកើតឡើងរួចហើយ។



**ស្មៅក្រពើ (Alligator weed)**

*Alternanthera philoxeroides*

- កាត់ និងលាបពណ៌
- ការដកចេញដោយដៃ
- ការស្រោបផ្នែកដើមដែលជាប់ឫស
- ការបាញ់ថ្នាំ
- ការដកចេញដោយម៉ាស៊ីន
- ទំនាក់ទំនងជាមួយសាលាសង្កាត់
- ការត្រួវាត់កាប់ និងការដាក់សំរាមគ្របកុំឱ្យដីហួត
- កោស និងលាបពណ៌



**ដើមត្រែងយក្ស (Giant reed)**

*Arundo donax*



**Green cestrum**

*Cestrum parqui*



**Ludwigia**

*Ludwigia peruviana*



**ស្មៅ Pampas grass**

*ប្រភេទ Cortaderia*



**Scotch/English broom**

*Cytisus scoparius*



**កំប្លោក (Water hyacinth)**

*Eichhornia crassipes*

# វិធីសាស្ត្រគ្រប់គ្រងស្មៅចង្រៃ

នៅក្រោមផ្នែកទី 3 *នៃច្បាប់ជីវសន្តិសុខឆ្នាំ 2015* - **កាតព្វ**កិច្ចជីវសន្តិសុខទូទៅចែងថាបុគ្គលណាម្នាក់ដែលដឹង ឬគួរតែដឹងដោយសមហេតុផលពីហានិភ័យជីវសន្តិសុខដែលបង្កឡើង ឬទំនងជាត្រូវបានបង្កឡើងដោយដោយសារធាតុជីវសន្តិសុខនៅលើដីរបស់ពួកគេ ត្រូវមានការព្វកិច្ចជីវសន្តិសុខដើម្បីធានាថា ដល់កម្រិតដែលអាចអនុវត្តបានដោយសមហេតុផល ត្រូវទប់ស្កាត់ លុបបំបាត់ ឬកាត់បន្ថយហានិភ័យជីវសន្តិសុខនោះ។

**ការពិចារណាអំពីសុវត្ថិភាព** - ការប្រុងប្រយ័ត្នទូទៅខាងក្រោមគួរតែបានធ្វើឡើងនៅពេលប្រើថ្នាំសម្លាប់ស្មៅ។ អានស្លាកមុនពេលបើកធុង ហើយធ្វើតាមការណែនាំនានា។

ពាក់សម្លៀកបំពាក់ការពារដូចដែលបានណែនាំនៅលើស្លាក ហើយលាងដៃក្រោយពេលប្រើ និងមុនពេលបរិភោគអាហារ។

គំនូរព្រាងទាំងអស់ដោយ Virginia Bear

### កាត់ និងលាបពណ៌

មានប្រយោជន៍សម្រាប់ស្មៅចង្រៃដូចដើមឈើដែលមានទំហំតូចទៅមធ្យមដែលមានអង្កត់ផ្ចិត 10 សង់ទីម៉ែត្រ។

ធ្វើការកាត់ផ្តេកឱ្យជិតដីតាមដែលអាចធ្វើទៅបាន ដោយប្រើកូនកន្ត្រៃកាត់មែកឈើ ឬកន្ត្រៃធំកាត់មែកឈើ ហើយលាបថ្នាំខាប់ Glyphosate ភ្លាមៗទៅលើផ្ទៃគល់ដែលលាតត្រដាង។

កុំឱ្យផ្ទៃត្រូវបានគ្របដោយដី។

គួរលាបសារធាតុគីមីក្នុងរយៈពេល 30 វិនាទីបន្ទាប់ពីបានកាត់។





### កាត់ផ្នែកដើមដែលជាប់ឫស

សម្រាប់ការព្យាបាល Blackberry។ កោសដីដែលនៅជុំវិញគល់រុក្ខជាតិនីមួយៗ រហូតទាល់តែមើលឃើញមើម (កន្លែងដែលផ្នែកដើមឈើលេចចេញមក)។

ដោយប្រើកូនកន្ត្រៃកាត់មែកឈើ ឬកន្ត្រៃធំកាត់មែកឈើ កាត់ឫសត្រង់ចំណុចធំបំផុត ហើយលាបថ្នាំខាប់ Glyphosate ឱ្យបានភ្លាមៗ។



### ការចាក់ និងការបំពេញដើម

នៅត្រង់គល់ដើមឈើ ខួងរន្ធនៅមុំ 45 ដឺក្រេ ចូលទៅក្នុងសំបកឈើ (នៅក្រោមសំបកខាងក្រៅ) នៅចន្លោះប្រហែលម្រាមដៃពីរជុំវិញគល់ទាំងមូលនៃដើមឈើ ចាក់ចែងដំណើរការនេះម្តងទៀតនៅខាងក្រោមមែកដែលទាបបំផុត។

កាត់ចូលទីក្នុងសំបកឈើដោយប្រើពន្លាក ឬពូថៅ។ បំពេញរន្ធ/កន្លែងកាត់នីមួយៗដោយប្រើថ្នាំសម្លាប់ស្មៅឱ្យបានភ្លាមៗ។

### ការពិចារណាសម្រាប់ការចាក់ និងការបំពេញដើម



រុក្ខជាតិគួរតែមានសុខភាពល្អ និងលូតលាស់យ៉ាងសកម្ម។

គួរតែព្យាបាលរុក្ខជាតិ Deciduous នៅនិទាឃរដូវ និងរដូវស្លឹកឈើជ្រុះ នៅពេលស្លឹកដុះចេញយ៉ាងពេញលេញ។

ចំពោះរុក្ខជាតិដែលមានដើមច្រើន ត្រូវចាក់ ឬចិតនៅក្រោមមែកដែលទាបបំផុត ឬព្យាបាលដើមនីមួយៗដោយឡែកពីគ្នា។

ថ្នាំសម្លាប់ស្មៅត្រូវតែចាក់ភ្លាមៗមុនពេលកោសិការុក្ខជាតិបិទ (ក្នុងរយៈពេល 30 វិនាទី ហើយឈប់ការប្តូរទីតាំងថ្នាំសម្លាប់ស្មៅ)។

### ● ការដកចេញដោយដៃ



យកគ្រាប់ពូជ ឬផ្លែឈើចេញថ្នមៗ ហើយដាក់ក្នុងថង់ដោយប្រុងប្រយ័ត្ន។

ចាប់មែកដល់កម្រិតដី។ អង្រន់រុក្ខជាតិ Plant ទៅមុខទៅក្រោយដើម្បីបន្ធូរឫស ហើយទាញចេញដោយថ្នមៗ។

ទះឫសថ្នមៗដោយប្រុងប្រយ័ត្នដើម្បីយកចេញដី។

ដាក់ជំនួសដីដែលបានយកចេញនោះ ហើយស្ទាបចុះក្រោម។

### ● កោស និងលាបពណ៌



ប្រើកាំបិត កោសដើមរហូតដល់ 1 ម៉ែត្រ រហូតទៅដល់ស្រទាប់ខាងក្រោមសំបក/ស្រទាប់ខាងក្រៅ។ បាញ់ថ្នាំសម្លាប់ស្មៅភ្លាមៗនៅតាមបណ្តោយកន្លែងកោស។

#### ការពិចារណា

គួរតែកោសពាក់កណ្តាលបន្ទាត់ផ្ចិតនៃទងជាអតិបរិមា។

**កុំស្រោបព័ទ្ធជុំវិញសំបក។** ដើមធំ ទាបជាង (> 1 សង់ទីម៉ែត្រ) គួរតែមានស្នាមកោសពីរទល់មុខគ្នា។

អាចព្យួរចោលដើមវល្លិនានានៅលើដើមឈើបន្ទាប់ពីការព្យាបាល លើកលែងតែដើមវល្លិ Maderia។

## ● ការស្រោបផ្នែកដើមដែលជាប់ឫស

យកដើមចេញថ្នមៗ ហើយខ្ចប់ជាមួយគ្រាប់ ឬផ្លែ។

ចាប់ស្លឹក ឬដើមឱ្យជាប់គ្នា ដើម្បីឱ្យអាចមើលឃើញគល់រុក្ខជាតិ។

ស៊កកាំបិត ឬដងថ្លឹងនៅចំមុំមួយ នៅក្បែរ 'ផ្នែកដើមដែលជាប់ឫស'។ កាត់ឫសទាំងអស់នៅជុំវិញផ្នែកដើមដែលជាប់ឫស។ យកចេញផ្នែកដើមដែលជាប់ឫស ហើយដាក់វាក្នុងថង់។



## ● ការដកចេញដោយម៉ាស៊ីន

អាចប្រើគ្រឿងចក្រឯកទេសដើម្បីដកដើមឈើ និងគល់ឈើ ដែលមានទំហំពីមធ្យមទៅធំ។




## ● ការព្យាបាលដោយប្រើថ្នាំសម្លាប់ស្មៅ - ការជូតដើម

យកគ្រាប់ពូជ ឬផ្លែឈើចេញថ្នមៗ ហើយដាក់ក្នុងថង់ដោយប្រុងប្រយ័ត្ន។ ដោយប្រើឧបករណ៍បាញ់ថ្នាំសម្លាប់ស្មៅ ជូតដើម/ស្លឹក។



## ● ការបាញ់ថ្នាំ

### ការពិចារណា

សូមអានស្លាកវិធីសាស្ត្រសមស្រប និងអនុវត្តអគ្រោសម្រាប់រុក្ខជាតិនីមួយៗដែលកំពុងបាញ់ថ្នាំជានិច្ច។

សិក្សា និងស្វែងយល់ពីរបៀបដែលថ្នាំសម្លាប់ស្មៅដំណើរការ - សម្រាប់ប្រភេទមើម និង មើមរាងមូល ពេលវេលាដែលមានប្រសិទ្ធភាពបំផុតគឺក្រោយពេលចេញផ្កា និងមុនពេលចេញផ្លែ។

តើអ្នកបានដោះស្រាយបញ្ហាសុវត្ថិភាពទាំងអស់ហើយឬនៅ?



### ការចោលសារធាតុស្មៅចង្រៃ

ស្មៅចង្រៃមានជាតិឈើជាច្រើនអាចត្រូវបានកិនកំទេចតាមរយៈកម្មវិធីកិនកំទេចនៅម្ខាងចិញ្ចើមថ្នល់ (Kerbside Chipping Program) របស់សាលាសង្កាត់ និងមជ្ឈមណ្ឌលទម្លាក់កាកសំណល់បៃតង។

ទោះយ៉ាងណាក៏ដោយមានករណីលើកលែងមួយចំនួន។ សារធាតុស្មៅចង្រៃដូចជា Scotch ឬ Cape Broom មិនគួរត្រូវបានកិនកំទេចទេនៅពេលកំពុងចេញគ្រាប់ពូជ។ សារធាតុស្មៅចង្រៃដែលមិនអាចកិនកំទេច គួរតែត្រូវបានបោះចោលក្នុងធុងសំរាមបៃតងរបស់អ្នក។

**Willows -** មិនគួរត្រូវបានកិនកំទេចទេ ពីព្រោះវាអាចដុះពន្លកឡើងវិញ

**ឫស្សី -** នេះក៏គួរត្រូវបានបោះចោលទៅក្នុងធុងបៃតងរបស់អ្នកផងដែរ។

# ចំណាំ

# ចំណាំ



រុក្ខជាតិផ្លាស់ប្តូរពីប្រភេទដីឥដ្ឋ និងដីក្រួស

FairfieldCity
Celebrating diversity

សាលាសង្កាត់នឹងរីករាយក្នុងការផ្តល់ព័ត៌មាន
បន្ថែម។

## ព័ត៌មានទំនាក់ទំនង៖


សាលាក្រុង Fairfield (Fairfield City Council)

86 Avoca Road, Wakeley NSW  2176

PO Box  21 Fairfield NSW 1860

(02) 9725 0222


ថ្ងៃចន្ទ ដល់ សុក្រ ពីម៉ោង 8.30 ព្រឹក ដល់ម៉ោង
4.30 ល្ងាច